# សេចក្តីថ្លែងការណ៍រួម

នេះគឺជាសេចក្តីថ្លែងការណ៍រួម រវាងធនាគារហត្ថា (HTB) និង ដើមបណ្តឹងពាក់ព័ន្ធនឹងការវិនិយោគរបស់ IFC ជាមួយធនាគារអេស៊ីលីដា ភីអិលស៊ី (លេខគម្រោង IFC 42480, 44882 និង 38609) និងធនាគារហត្ថា ភីអិលស៊ី (លេខគម្រោង IFC 44742) ក្នុងប្រទេសកម្ពុជា។ ពាក្យបណ្តឹងនេះ ត្រូវបានដាក់ឈ្មោះសម្គាល់ថា “Cambodia: ACLEDA and HTB-14”។

ក្នុងអំឡុងពេលនៃដំណើរការវាយតម្លៃរបស់ CAO ផ្នែកនៃពាក្យបណ្តឹងដែលទាក់ទងនឹងធនាគារអេស៊ីលីដា ត្រូវបានដោះស្រាយតាមរយៈការចូលរួមដោយផ្ទាល់ ស្របតាមកថាខណ្ឌទី ៥៥ នៃគោលនយោបាយរបស់ CAO។ បន្ថែមពីនេះ ដើមបណ្តឹង និងអតិថិជនរបស់ IFC គឺ ធនាគារហត្ថា (HTB) បានសម្តែងការចាប់អារម្មណ៍ ចូលរួមក្នុងដំណើរការដោះស្រាយវិវាទដែលសម្របសម្រួលដោយ CAO ដើម្បីដោះស្រាយបញ្ហាដែលបានលើកឡើងនៅក្នុងពាក្យបណ្តឹងពាក់ព័ន្ធនឹងធនាគារហត្ថា ដោយប្រើប្រាស់វិធីសាស្ត្រដែលមានការចូលរួមសហការ។ ភាគីទាំងពីរបានឯកភាពលើវិធានជាមូលដ្ឋាន សម្រាប់ការសម្រុះសម្រួល នៅក្នុងខែមករា ឆ្នាំ២០២៦។

ជាលទ្ធផលនៃការចូលរួមដោះស្រាយវិវាទដោយស្ម័គ្រចិត្តនេះ ភាគីទាំងពីរបានឈានដល់ និងបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយ នៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៦ និងបានឯកភាពថា ការតាមដានការអនុវត្តកិច្ចព្រមព្រៀងដោះស្រាយវិវាទនេះ មានរយៈពេល ២៤ ខែ ជាមួយនឹងលទ្ធភាពអាចបន្តបាន។

បន្ថែមពីនេះ ភាគីទាំងពីរ និងតំណាងរៀងៗខ្លួន បានឯកភាពរក្សាការសម្ងាត់នៃខ្លឹមសាររបស់កិច្ចព្រមព្រៀង ដើម្បីគោរពដល់ឯកជនភាពនៃដំណើរការនេះ ការពារព័ត៌មានរសើបផ្នែកពាណិជ្ជកម្ម និងគោរពដល់ការយោគយល់គ្នាទៅវិញទៅមករវាងភាគីទាំងពីរ។